ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
Ministry of Industry, Mines and Energy

លេខ : ៤០៤ ឧរម.អឧ.(ប)ក

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពីការកែសំរួលគោលនយោបាយឧបត្ថម្ភ សំរាប់បំពេញខាតឱ្យអតិថិជនប្រើប្រាស់អគ្គិសនី ប្រភេទលំនៅដ្ឋាន នៅរាជធានីភ្នំពេញនិងខេត្តកណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

-យោងសេចក្តីសម្រេចរបស់អង្គប្រជុំអន្តរក្រសួង នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០០៥ ដែលពិនិត្យអំពីបញ្ហាផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញនិងខេត្តកណ្តាលក្នុងសភាពការណ៍ដែលប្រេងឥន្ធនៈឡើងថ្លៃខ្ពស់

-បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៨៦២ សជណ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសំរួលគោលនយោបាយបំពេញខាតឱ្យអតិថិជនលំនៅដ្ឋាន និងការកែសំរួលថ្លៃលក់អគ្គិសនីឱ្យអតិថិជនប្រភេទអាជីវកម្ម ពាណិជ្ជកម្ម និងឧស្សាហកម្ម ។

## សម្រេច

**ប្រការ ១ :** កែសំរួលគោលនយោបាយឧបត្ថម្ភ សំរាប់បំពេញខាតលើថ្លៃលក់អគ្គិសនីឱ្យអតិថិជនលំនៅដ្ឋានប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាលឡើងវិញ

៤៥ មហាវិថីព្រះនរោត្តម, ខ័ណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ-ទូរសារ ០២៣ ២១១ ១៤១
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh (Cambodia) tel/ Fax : (855) 23 211 141

**ប្រការ ២ :** ការឧបត្ថម្ភសំរាប់បំពេញខាតលើថ្លៃលក់អគ្គិសនី គឺផ្តល់ឱ្យចំពោះតែលំនៅដ្ឋានប្រជាពលរដ្ឋកម្ពុជាដែលមានការខ្វះខាតពិតប្រាកដ និងដែលបានប្រើប្រាស់អគ្គិសនីដោយសន្សំសំចៃមិនលើសពីចំនួនថាមពលដែលកំណត់ឱ្យប្រើប្រាស់ប្រចាំខែប៉ុណ្ណោះ ។ លំនៅដ្ឋានដែលមានការខ្វះខាតពិតប្រាកដ ត្រូវបែងចែកជា២ប្រភេទ គឺលំនៅដ្ឋានខ្វះខាតខ្លាំង និង លំនៅដ្ឋានខ្វះខាតមធ្យម ។ លំនៅដ្ឋានខ្វះខាតខ្លាំង គឺលំនៅដ្ឋានទាំងឡាយណាដែលប្រើប្រាស់អគ្គិសនីមិនលើសពី ៥០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ ។ លំនៅដ្ឋានខ្វះខាតមធ្យម គឺលំនៅដ្ឋានទាំងឡាយណាដែលប្រើប្រាស់អគ្គិសនីលើសពី ៥០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ ប៉ុន្តែមិនលើស ១០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ ។

**ប្រការ ៣ :** លំនៅដ្ឋានខ្វះខាតខ្លាំងដែលប្រើប្រាស់អគ្គិសនីមិនលើសពី ៥០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ ត្រូវបានអនុគ្រោះឱ្យបង់ថ្លៃអគ្គិសនីត្រឹម ៣៥០ រៀលក្នុង១គីឡូវ៉ាត់ម៉ោងដូចមុន ដោយរដ្ឋជាអ្នកឧបត្ថម្ភបំពេញបន្ថែមឱ្យ តាមគោលការណ៍ឧបត្ថម្ភបំពេញខាតដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ ។ ការអនុគ្រោះនេះផ្តល់ឱ្យ តាមលក្ខខណ្ឌនៃការប្រើប្រាស់អគ្គិសនីប្រចាំខែរបស់អ្នកប្រើប្រាស់ ។

**ប្រការ ៤ :** លំនៅដ្ឋានខ្វះខាតមធ្យមដែលប្រើអគ្គិសនីលើសពី ៥០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ ប៉ុន្តែមិនលើស ១០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ ត្រូវបានអនុគ្រោះឱ្យបង់ថ្លៃអគ្គិសនីត្រឹម ៥៥០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង ដោយរដ្ឋជាអ្នកឧបត្ថម្ភបំពេញបន្ថែមឱ្យ តាមគោលការណ៍ឧបត្ថម្ភបំពេញខាតដូចមាន ចែងក្នុងប្រការ ៦ នៃប្រកាសនេះ ។ ការអនុគ្រោះនេះផ្តល់ឱ្យ តាមលក្ខខណ្ឌនៃការប្រើប្រាស់អគ្គិសនីប្រចាំខែរបស់អ្នកប្រើប្រាស់ ។

**ប្រការ ៥ :** លំនៅដ្ឋានទាំងឡាយដែលបានប្រើអគ្គិសនីច្រើនលើសពី ១០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ មិនត្រូវបានចាត់ទុកថាជាលំនៅដ្ឋានខ្វះខាតឡើយ ។ លំនៅដ្ឋានទាំងនោះត្រូវទូទាត់ការប្រើប្រាស់អគ្គិសនីតាមអត្រាថ្លៃលក់អគ្គិសនីពេញលេញ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ បច្ចុប្បន្នអត្រាថ្លៃលក់អគ្គិសនីពេញលេញរបស់អតិថិជនលំនៅដ្ឋាន នៅរាជធានីភ្នំពេញនិងខេត្តកណ្តាលគឺ ៦៥០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង ។

**ប្រការ ៦ :** ការឧបត្ថម្ភបំពេញខាតឱ្យលំនៅដ្ឋានដែលមានការខ្វះខាតដូចចែងក្នុងប្រការ២ខាងលើ ត្រូវអនុវត្តតាមគោលការណ៍ឧបត្ថម្ភបំពេញឱ្យគ្នាទៅវិញទៅមករវាងប្រភេទអតិថិជនផ្សេងៗនៅ

ក្នុងបញ្ជីថ្លៃលក់អគ្គិសនី សំរាប់ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅក្នុងរាជធានីភ្នំពេញនិងខេត្តកណ្តាល ។ គោលការណ៍នេះគឺជាមូលដ្ឋានសំរាប់អាជ្ញាធរអគ្គិសនីកម្ពុជាកំណត់បញ្ជីថ្លៃលក់អគ្គិសនី ស្របតាមខ្លឹមសារដែលមានចែងក្នុងមាត្រា ៤៨ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៧ :** អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គនាយកដ្ឋានថាមពល ក្រុមហ៊ុនអគ្គិសនីកម្ពុជា ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និង ខេត្តកណ្តាលត្រូវអនុវត្តតាមមុខការរៀងៗខ្លួន ។

**ប្រការ ៨ :** រាល់ប្រកាសនិងសេចក្តីសម្រេចផ្សេងទៀតដែលមានខ្លឹមសារផ្ទុយពីខ្លឹមសារនៃប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ_សែម

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលាក្រុងភ្នំពេញ
-សាលាខេត្តកណ្តាល
-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-អាជ្ញាធរអគ្គិសនីកម្ពុជា
"ដើម្បីរៀបចំកែសំរួលខ្លឹមសារបញ្ជីថ្លៃលក់អគ្គិសនីជាថ្មី"
-ក្រុមហ៊ុនអគ្គិសនីកម្ពុជា
"ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
-ឯកសារ-កាលប្បវត្តិ
-រាជកិច្ច ឯកសារ